ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៣០៩៣ MIH / ២០១៧

# សេចក្តីណែនាំ
# ស្តីពី
# ការអនុវត្តប្រកាសលេខ ១០៧ MIH/2017 ស្តីពី ការកំណត់សញ្ញាផលិតផលកម្ពុជាមានគុណភាព

ដើម្បីអនុវត្តប្រកាសលេខ ១០៧ MIH/2017 ស្តីពីការកំណត់សញ្ញាផលិតផលកម្ពុជាមានគុណភាព ឱ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងគោលបំណងឱ្យផលិតផលដែលបានអនុលោមតាម លក្ខណៈបច្ចេកទេសត្រឹមត្រូវ មានការចុះបញ្ជីផលិតផល(ចបផ) ឬស្តង់ដាអនុលោម និងលក្ខខណ្ឌមាត្រាសាស្ត្រ ជាផលិតផលមានគុណភាព សុវត្ថិភាព និងសោភ័ណភាពស្របតាមការកំណត់អាចបម្រើទីផ្សារប្រកបដោយទំនុកចិត្ត និងការជឿជាក់។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សូមណែនាំដល់ម្ចាស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ទាំងអស់ដែលមានប្រកាស បង្កើតរោងចក្រ ឬចុះបញ្ជីសហគ្រាសសិប្បកម្ម និងវិញ្ញាបនបត្រអនុញ្ញាតដំណើរការ និងមានបំណងប្រើប្រាស់ស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាព ក្រសួងនឹងពិនិត្យផ្តល់សញ្ញាផលិតផលកម្ពុជា មានគុណភាពជូន ដោយម្ចាស់ត្រូវមកបំពេញបែបបទ និងការពារផលិតផលរបស់ខ្លួននៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដូចមាននីតិវិធីដូចខាងក្រោម ៖

## ១. អំពីទម្រង់បែបបទស្នើសុំមាន ៖

- ពាក្យស្នើសុំប្រើប្រាស់សញ្ញាផលិតផលកម្ពុជាមានគុណភាព
- ប្រកាសអនុញ្ញាតបង្កើតរោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម
- វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម
- អាជ្ញាប័ណ្ណសម្រាប់ប្រើសញ្ញាចុះបញ្ជីផលិតផល (ចបផ) ឬវិញ្ញាបនបត្រផលិតផល និងអាជ្ញាប័ណ្ណប្រើសញ្ញាបញ្ជាក់ផលិតផល
- លទ្ធផល ឬវិញ្ញាបនបត្រត្រួតពិនិត្យ ផ្ទៀងផ្ទាត់ទំនិញផលិត និងទំនិញវេចខ្ចប់

ម្ចាស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម អាចទទួល និងបំពេញឯកសារខាងលើនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឬទាញយកពីគេហទំព័ររបស់ក្រសួង www.mih.gov.kh

## ២. អំពីនីតិវិធីដំណើរការឯកសារ

ម្ចាស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ត្រូវដាក់ពាក្យ និងឯកសារស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយបង់កម្រៃសេវាសាធារណៈស្រប



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com

តាមប្រកាសអន្តរក្រសួង រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តម្លៃ ៥០០.០០០ (ប្រាំរយពាន់) រៀល ក្នុងមួយមុខផលិតផល។

ពាក្យ និងឯកសារស្នើសុំ ត្រូវបញ្ជូនទៅលេខាធិការដ្ឋាន នៅអគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ដើម្បីបញ្ជូនមកគណៈកម្មការផ្តល់សញ្ញាផលិតផលកម្ពុជាមានគុណភាព។

គណៈកម្មការ ផ្តល់សញ្ញាផលិតផលកម្ពុជាមានគុណភាព នឹងធ្វើការកោះប្រជុំដើម្បីពិនិត្យ និងវាយតម្លៃលើ៖

- ភាពគ្រប់គ្រាន់ និងត្រឹមត្រូវនៃឯកសារតម្រូវ
- ការពិនិត្យលើខ្សែសង្វាក់ផលិតកម្មក្នុងករណីចាំបាច់
- សំណាកគំរូផលិតផល ដោយមានការចូលរួមពីម្ចាស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម
- ការរៀបចំ និងបង្ហាញអំពីសញ្ញាសម្គាល់នៅលើសំបកវេចខ្ចប់ មាន៖ **ចបផ ឬសញ្ញាស្តង់ដា** ចំណុះ ទម្ងន់ បរិមាណ កាលបរិច្ឆេទផលិត និងផុតកំណត់ការប្រើប្រាស់ សមាសធាតុផ្សំ លក្ខខណ្ឌរក្សាទុក សោភ័ណភាពវេចខ្ចប់ របៀបប្រើប្រាស់ និងការរំលឹកអំពីហានិភ័យនៃការប្រើប្រាស់។

ក្នុងករណីពុំទាន់បំពេញលក្ខខណ្ឌខ្លះខាងលើបាន ម្ចាស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ត្រូវកែលម្អតាមការកំណត់របស់គណៈកម្មការ ដោយផ្អែកលើគោលការណ៍សម្របសម្រួល។ ក្រោយពីបានសម្របសម្រួល និងឯកភាព គណៈកម្មការនឹងពិនិត្យសម្រេចផ្តល់ស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាព។

បញ្ជាក់៖

- ក្នុងករណីខ្សែសង្វាក់ផលិតកម្មរបស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ពុំទាន់ធានាបាននូវអនាម័យ ការរៀបចំបរិស្ថានក្នុងទីតាំងផលិតកម្ម ពុំសមស្របតាមលក្ខខណ្ឌតម្រូវ ត្រូវកែលម្អឡើងវិញដោយធានាលក្ខណៈសមស្រប ទើបអាចសម្រេចអនុញ្ញាតផ្តល់ជូនសញ្ញាផលិតផលកម្ពុជាមានគុណភាព។
- ក្នុងករណីម្ចាស់មូលដ្ឋានធ្វើការផ្លាស់ប្តូរខ្សែសង្វាក់ផលិតកម្ម ឬសមាសធាតុផ្សំ ត្រូវធ្វើការស្នើសុំស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាពសាជាថ្មី។

### ៣. អំពីរយៈពេលពិនិត្យ និងផ្តល់ស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាព

គណៈកម្មការផ្តល់សញ្ញាផលិតផលកម្ពុជាមានគុណភាព នឹងធ្វើការប្រជុំពិនិត្យ និងវាយតម្លៃលើសំណើរបស់ម្ចាស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ក្នុងមួយខែម្តង។ ចំពោះសំណើដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងផ្តល់វិញ្ញាបនបត្រជូន ដោយមានសុពលភាព ០៣ (បី)ឆ្នាំ។ រយៈពេលឆ្លើយតបចំពោះសំណើសុំស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាព យ៉ាងយូរបំផុត



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mih.smcabinet@gmail.com

៣៥ ថ្ងៃនៃថ្ងៃធ្វើការ(សាមសិបប្រាំ) ចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។ មុនផុតកំណត់ ៦០ថ្ងៃ ម្ចាស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ត្រូវដាក់ពាក្យស្នើសុំបន្ត។ ចំពោះស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាពដែលត្រូវបិទ ឬបោះពុម្ពលើផលិតផល ត្រូវដាក់ការបញ្ជាក់កាលបរិច្ឆេទផុតកំណត់ នៃស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាព បង្ហាញភ្ជាប់ខាងក្រោមស្លាកសញ្ញា ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យ។

- ទំហំអប្បបរមា នៃស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាពដែលត្រូវបិទ ឬបោះពុម្ព មានអង្កត់ផ្ចិត ១៥មីលីម៉ែត្រ។

**៤ .អំពីការផ្តល់ស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាព៖**

- ការអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាព ត្រូវបានផ្តល់ជាវិញ្ញាបនបត្រ ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម។
- ម្ចាស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មមានសិទ្ធិប្រើប្រាស់ស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាពលើផលិតផលរបស់ខ្លួនក្រោយពីទទួលបានវិញ្ញាបនបត្រ។
- ស្លាកសញ្ញាផលិតផលកម្ពុជាមានគុណភាពត្រូវកត់ត្រាបញ្ចូលទៅក្នុងទិន្នន័យ QR Code ដើម្បីតាមដាន និងការពារការក្លែងបន្លំ។

៥. ក្រោយពីគណៈកម្មការ គសកគ បានសម្រេចអនុញ្ញាតឱ្យប្រើប្រាស់សញ្ញាផលិតផលកម្ពុជាមានគុណភាពជាផ្លូវការរួច ម្ចាស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ត្រូវមានកាតព្វកិច្ចយកផ្លាកសញ្ញាដែលបានបោះពុម្ពជាស្ទីកឃ័រសម្រាប់បិទពីលើផលិតផល ឬបោះពុម្ពលើស្លាកផលិតផលតាមទំហំដែលបានកំណត់ខាងលើ យកមកតម្កល់ទុកនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីរក្សាទុក និងផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃគំរូផ្លាកសញ្ញាដែលបានអនុញ្ញាត។

អគ្គនាយកដ្ឋាន វិទ្យាស្ថាន មជ្ឈមណ្ឌល នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងម្ចាស់រោងចក្រ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ បុស្ស ឆ្នាំរកា ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- គ្រប់អគ្គនាយកដ្ឋានចំណុះក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- វិទ្យាស្ថានស្តង់ដាកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- គ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ឯកសារ-កាលប្បវត្តិ